# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ការពិចារណាពីសន្ធិសញ្ញាបំពេញបន្ថែមដែលធ្វើឲ្យខ្មែរបាត់បង់ទឹកដីទៅវៀតណាមពិតមែនឬទេ ?

**Website: www.hoksavann.org**

ថ្ងៃទី២៨ វិច្ឆិកា ២០០៩



យើងសូមដកស្រង់ឯកសារខ្លះ ដែលសរសេរដោយអ្នកជំនាញការ ទាក់ទងនឹងបញ្ហាទឹកដីព្រំប្រទល់ដែនរវាងប្រទេសកម្ពុជានិងប្រទេសវៀតណាម សំរាប់ជនជាតិខ្មែរស្នេហាជាតិយកទៅពិចារណា ។

បន្ទាប់ពីកងទ័ពវៀតណាមចូលមកកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩មក សាធារណរដ្ឋប្រជាមានិតុកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានធ្វើសន្ធិសញ្ញាជាបន្តបន្ទាប់ដូចតទៅនេះ ៖

★ ថ្ងៃទី១៨ កុម្ភៈ ១៩៧៩ ៖ សន្ធិសញ្ញាសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ ចុះហត្ថលេខាដោយផាំ-វ៉ាន់ដុង រដ្ឋមន្ត្រីទី១វៀតណាម និងហេង-សំរិន ប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ។

★ ថ្ងៃទី៧ កក្កដា ១៩៨២ ៖ កិច្ចព្រមព្រៀងស្តីពីទឹកប្រវត្តិសាស្ត្រ ចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសវៀតណាម ង្វៀង-កូថាច់ និងហ៊ុន-សែន ។

★ ថ្ងៃទី២០ កក្កដា ១៩៨៣ ៖ សន្ធិសញ្ញាស្តីពីគោលការណ៍ដើម្បីដោះស្រាយព្រំដែន រវាងសាធារណរដ្ឋប្រជាមានិតុកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះហត្ថលេខាដោយង្វៀង-កូថាច់ និងហ៊ុន-សែន ។ ថ្ងៃខែឆ្នាំដដែលបានបន្ថែមកិច្ចព្រមព្រៀងស្តីពីលក្ខន្តិកៈព្រំដែនរវាងប្រទេសទាំងពីរ ។

★ ថ្ងៃទី២៧ ធ្នូ ១៩៨៥ ៖ សន្ធិសញ្ញាកំណត់ព្រំដែនរវាងសាធារណរដ្ឋប្រជាមានិតុកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះហត្ថលេខាដោយង្វៀង-កូថាច់ និងហ៊ុន-សែន ។

ក្រោយមក ហេតុអ្វីបានជាកើតសន្ធិសញ្ញាបំពេញបន្ថែម ? យើងយល់ថា បានជាមានសន្ធិសញ្ញាបំពេញបន្ថែម ព្រោះរដ្ឋាភិបាលវៀតណាមយល់ច្បាស់ថា សន្ធិសញ្ញាទាំងពីរពុំស្របច្បាប់ឡើយ ដោយវៀតណាមខ្លួនឯងចូលមកត្រួតត្រាប្រទេសកម្ពុជាដោយកម្លាំងទ័ព ហើយតែងតាំងរដ្ឋាភិបាលខ្មែរ ហៅថារដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតុកម្ពុជានេះឯង ។ នេះរាជរដ្ឋាភិបាលចំរុះកើតឡើងដោយការបោះឆ្នោតត្រឹមត្រូវតាមរបបប្រជាធិបតេយ្យ ទើបវៀតណាមបង្ខំឲ្យរាជរដ្ឋាភិបាលចំរុះនេះ ដែលមានកូនចៅរបស់ខ្លួន គឺគណបក្សប្រជាជនកម្ពុជា នៅតែកាន់អំណាចកំពូលឲ្យធ្វើសន្ធិសញ្ញាបំពេញបន្ថែមនេះឡើង ។ សន្ធិសញ្ញាបំពេញបន្ថែមនេះបានឆ្លងកាត់រាជរដ្ឋាភិបាល ឆ្លងកាត់រដ្ឋសភា ទើបថ្ងៃទី៣០ វិច្ឆិកា ២០០៥ ព្រះមហាក្សត្រព្រះបរមនាថនរោត្តម-សីហមុនី បានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញាកំណត់ព្រំដែន ចុះថ្ងៃទី ២៧ ធ្នូ ឆ្នាំ១៩៨៥ ។ វៀតណាមបានអបអរយ៉ាងខ្លាំង ដោយបំណងរបស់ខ្លួនបានសំរេចដោយជោគជ័យ ដោយយល់ថាសន្ធិសញ្ញាមិនស្របច្បាប់ត្រូវបានធ្វើឲ្យស្របច្បាប់ហើយ ។ សកម្មជនសិទ្ធិមនុស្សនិងអ្នកប្រឆាំងខ្លះបានត្រូវចាប់ដាក់គុកដោយសារការប្រឆាំងនឹងសន្ធិសញ្ញាបំពេញបន្ថែមនេះ ។

យើងគួរពិចារណាមើលនូវសន្ធិសញ្ញាដែលមានភាពពុំស្មើគ្នានេះ ។ ប្រទេសវៀតណាមបានធ្វើអាណានិគមលើប្រទេសកម្ពុជាពេលនោះ ដូច្នេះប្រទេសកម្ពុជាពេលនោះ ក៏អស់ឯករាជ្យ អស់អធិបតេយ្យជាតិ គឺគ្មានការគ្រប់គ្រងជាតិដោយខ្លួនឯងទេ បន្ទាប់ពីពួកខ្មែរក្រហមបានដួលរលំទៅ ។ ពួកបញ្ញវ័ន្តខ្មែរ ពួកខ្មែរអ្នកចេះដឹងបានស្លាប់និងត្រូវគេសម្លាប់ស្ទើរតែទាំងអស់ទៅហើយ ។ ខ្មែរស្ថិតនៅក្រោមបង្គាប់គេ និងខ្វះអ្នកចេះដឹង តើអាចចាត់ទុកថាសន្ធិសញ្ញាទាំងនោះមានយុត្តិធម៌ឬទេ ?? ហើយបើសន្ធិសញ្ញាទាំងនោះមិនចំណេញដល់វៀតណាមទេ ហេតុអ្វីបានជាវៀតណាមចង់បានសន្ធិសញ្ញាទាំងនោះឲ្យស្របច្បាប់ គឺសន្ធិសញ្ញាបំពេញបន្ថែមនេះ ។ ពីព្រោះដោយសារសន្ធិសញ្ញានេះ តើខ្មែរត្រូវបាត់បង់ទឹកដីអស់ប៉ុន្មាន ?? ។

យើងសូមដកស្រង់ឯកសារមួយទៀតនិយាយថា វៀតណាមបានបោះបង្គោលសីមាព្រំដែនខ្មែរ-វៀតណាមបានខ្លះពីឆ្នាំ១៩៨៦ដល់១៩៨៨ តើបង្គោលទាំងនោះចាត់ជាត្រឹមត្រូវឬទេ ? បើបង្គោលទាំងនោះបោះនៅពេលដែលខ្មែរស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាម ។ អត្ថបទនោះបន្តទៀតថា ក្នុងដែនសមុទ្រខ្មែរ សេចក្តីព្រមព្រៀងឆ្នាំ១៩៨២បានកាត់យកសមុទ្រខ្មែរ៣០,០០០គម$^{២}$ ហើយបានបង្កើតនៅក្នុងដែនសមុទ្រខ្មែរ នូវសមុទ្រជាប្រវត្តិសាស្ត្រ១០,០០០គម$^{២}$ទៀត ក្រោមការត្រួតត្រារួមគ្នាខ្មែរ-វៀតណាម ។ មួយទៀត នៅថ្ងៃទី១១ សីហា ១៩៩៧, វៀតណាមនិងថៃបានធ្វើកិច្ចព្រមព្រៀងគ្នានៅលើផ្ទៃសមុទ្រ ដោយមិនបានសាកសួរខ្មែរឡើយ ។ កិច្ចព្រមព្រៀងនោះ ថៃបានកាត់ផ្តាច់៣០,០០០គម$^{២}$នៃផ្ទៃសមុទ្រខ្មែរ ។

បងប្អូនរួមជាតិខ្មែរ ! បើសន្ធិសញ្ញាទាំងនោះធ្វើឲ្យខ្មែរបាត់បង់ទឹកដី ហេតុអ្វីបានជាប្រោសឲ្យរស់ មិនលុបចោល ? តទៅនេះ យើងសូមលើកយកវគ្គមួយនៃសេចក្តីថ្លែងរបស់បណ្ឌិតសាយ-បូរី នៅថ្ងៃទី៨ កុម្ភៈ ២០០៣ នៅក្នុងកិច្ចប្រជុំមួយដែលរៀបចំឡើងដោយគ្រឹះសម្ព័ន្ធខ្មែរ នៅសាកលវិទ្យាល័យមួយនាវ៉ាស៊ិនតោនឌីស៊ីសហរដ្ឋអាមេរិកថា ៖ «**ខ្ញុំគ្រាន់តែជំរាបថា ល្អឹកណាព្រះមហាក្សត្រខ្មែរមិនឡាយព្រះហត្ថលេខា ផ្តល់សច្ចាប័នដល់សន្ធិសញ្ញាបន្ថែមណាមួយឲ្យវៀតណាម សន្ធិសញ្ញា**

**ទាំង៥នោះស្លាប់ឯង ដោយមិនបាច់ប្រកាសលុបចោលក៏បាន ។ ប៉ុន្តែបើរាជរដ្ឋាភិបាលប្រការលុបចោលជាផ្លូវការ វារឹតតែប្រសើរណាស់ទៅទៀត ។ បងប្អូនរួមឈាមអ្នកស្នេហាជាតិទាំងក្នុងនិងក្រៅប្រទេស ត្រូវបន្តសកម្មភាពតទៅទៀត ដើម្បីកុំឲ្យសន្ធិសញ្ញាបន្ថែមកើតមានបាន ។ បើគ្មានអ្វីមកបន្ថែមទេ សន្ធិសញ្ញាហ្នឹងតាមផ្លូវច្បាប់ វានៅតែងាប់ដដែល**» ។ សេចក្តីថ្លែងនេះធ្វើមុនព្រះមហាក្សត្រខ្មែរឲ្យសច្ចាប័នសន្ធិសញ្ញានេះពីរឆ្នាំ ។

យើងឃើញឯកសារក្នុងវគ្គមួយទៀតសរសេរថា កិច្ចព្រមព្រៀងឆ្នាំ១៩៨២នាំឲ្យខ្មែរបាត់កោះ២ គឺកោះត្រល់និងកោះក្រចកសេះជាស្ថាពរ ដែលមានសេចក្តីដូចតទៅនេះ ៖ «កិច្ចព្រមព្រៀងស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ ចុះថ្ងៃទី៧ កក្កដា ១៩៨២ ដែលបានចុះហត្ថលេខាដោយលោកង្វៀង-កូថាច់ជាមួយនិងលោកហ៊ុន-សែន រដ្ឋមន្ត្រីក្រសួងការបរទេស ។ កិច្ចព្រមព្រៀងនេះបានប្រគល់កោះត្រល់និងកោះក្រចកសេះទៅឲ្យយួនផ្តាច់ជាស្ថាពរ ថ្វីបើនៅថ្ងៃទី៣០ ធ្នូ ឆ្នាំ១៩៥៧ ព្រះករុណាព្រះបាទសុរាម្រិត បានចេញព្រះរាជក្រឹត្យបញ្ជាក់អំពីការរក្សាទុកនូវសិទ្ធិរបស់ប្រទេសខ្មែរលើកោះនោះក៏ដោយ ។ នៅថ្ងៃទី៧ មិថុនា ១៩៥៧, សម្តេចព្រះនរោត្តម-សីហនុ ក្នុងឋានៈជានាយករដ្ឋមន្ត្រី បានបញ្ជាឲ្យរាជរដ្ឋាភិបាលចាត់វិធានការរក្សាការពារកោះក្រចកសេះ ។ តែនៅពេលខ្មែរទៅដល់កោះនោះ គេឃើញទ័ពយួនចូលទៅកាន់កាប់មុនស្រេចទៅហើយ» ។ បើតាមសេចក្តីនៅក្នុងវគ្គនេះបញ្ជាក់ថា បន្ទាប់ពីខ្មែរបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ កោះទាំងពីរនោះពុំទាន់បានទៅប្រទេសណានៅឡើយទេ គ្រាន់តែយួនយកទ័ពទៅកាន់កាប់មុនប៉ុណ្ណោះ តែនៅមានសិទ្ធិទាមទារដូចសេចក្តីបញ្ជាក់របស់ព្រះករុណាព្រះបាទសុរាម្រិត ។ តែគួរឲ្យស្តាយ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលយួនត្រួតត្រា បានប្រគល់កោះទាំងពីរនេះឲ្យយួនតែម្តងក្នុងកិច្ចព្រមព្រៀងឆ្នាំ១៩៨២ ។ បើព្រឹត្តការណ៍ជាប្រវត្តិសាស្ត្រនេះកើតមានបែបនេះមែន តើជនរួមជាតិខ្មែរគិតបែបម៉េចដែរ ? ។

តទៅនេះ យើងសូមលើកយកវគ្គខ្លះនៃកិច្ចព្រមព្រៀងសន្តិភាពខ្មែរថ្ងៃទី២៣ តុលា ១៩៩១នៅទីក្រុងប៉ារីស ដែលបានចុះហត្ថលេខា១៩ប្រទេស ក្រោមអធិបតីភាពនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទាក់ទងនឹងបូរណភាពទឹកដីខ្មែរ។ កិច្ចព្រមព្រៀងនោះមាន៨មាត្រា ។ ត្រង់ជំពូក១ អក្សររៀង (ឃ) ចែងថា បញ្ចប់សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយដែលមិនសមស្របទៅនឹងអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អាព្យាក្រឹត្យ និងឯកភាពជាតិកម្ពុជា ។ មាត្រា៤ចែងថា ភាគីដែលចុះកិច្ចព្រមព្រៀងនេះ អំពាវនាវដល់រដ្ឋដទៃទៀត ឲ្យទទួលស្គាល់និងគោរពគ្រប់បែបយ៉ាង ដល់អធិបតេយ្យភាព ឯករាជ្យ និងបូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹត្យ និងឯកភាពជាតិរបស់កម្ពុជា ហើយជៀសវាងធ្វើអំពើ ដែលមិនសមស្របនឹងគោលការណ៍ទាំងនោះ ឬដែលមិនសមស្របទៅនឹងប្រការដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ។ មាត្រា៥ លេខរៀងទី១ចែងថា ក្នុងករណីមានការរំលោភ ឬការគំរាមកំហែងរំលោភលើអធិបតេយ្យ ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹត្យ ឬឯកភាពជាតិកម្ពុជា ឬលើការប្តេជ្ញាអនុវត្តដទៃទៀតណាមួយក្នុងកិច្ចព្រមព្រៀងនេះ បណ្តាភាគីក្នុងកិច្ចព្រមព្រៀងនេះធ្វើការពិគ្រោះជាបន្ទាន់ ដើម្បីអនុម័តរាល់វិធានការសមស្រប ដើម្បីធានាការគោរពដល់ការប្តេជ្ញាចិត្តទាំងនោះ និងដោះស្រាយរាល់ការរំលោភទាំងនោះ តាមមធ្យោ-បាយសន្តិវិធី ។ លេខរៀងទី២ មាត្រា៥ដដែលចែងថា វិធានការបែបនេះក្នុងចំណោមវិធានការផ្សេងទៀត អាចរួមមានការរាយការណ៍ទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬប្រើប្រាស់មធ្យោបាយដំណោះស្រាយនូវទំនាស់ដោយសន្តិវិធីយោងទៅតាមមាត្រា៣៣នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ល។

យោងតាមឯកសារប្រវត្តិសាស្ត្រស្តីពីកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជាថ្ងៃទី២៣តុលា១៩៩១នៅប៉ារីស ដែលបានដកស្រង់ក្នុងវគ្គខ្លះនេះបញ្ជាក់ថា ភាគីទាំង១៩ប្រទេសដែលបានចុះហត្ថលេខា ប្តេជ្ញាចិត្តគោរពឯករាជ្យ និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ហើយអំពាវនាវដល់ប្រទេសដទៃទៀតឲ្យគោរពដូចគ្នា ។ បើមានការរំលោភ ប្រទេសដែលបានចុះហត្ថលេខាប្រជុំគ្នាដោះស្រាយជាបន្ទាន់ ហើយអាចប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ សន្ធិសញ្ញាណាដែលធ្វើមុនកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ដល់ឯករាជ្យ បូរណភាពទឹកដីខ្មែរជាដើមត្រូវលុបចោល ។ បងប្អូនរួមជាតិនាំគ្នាពិ-ចារណា សន្ធិសញ្ញាដែលបានធ្វើមុនកិច្ចព្រមព្រៀងនេះ មិនត្រឹមតែមិនលុបចោលទេ ថែមទាំងធ្វើឲ្យស្របច្បាប់ថែមទៀតដែលហៅថាសន្ធិសញ្ញាបំពេញបន្ថែមនេះឯង ។ ស្របតាមន័យនេះដែរ យោងតាមធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ ត្រង់មាត្រាទី៥៥ចែងថា «**សន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនស្របនិងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹត្យ និងឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល**» ។

ឥឡូវនេះ អ្នកកាន់អំណាចទាំងបីនៃប្រទេសកម្ពុជា គឺប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងប្រមុខរាជរដ្ឋាភិបាលហាក់ដូចជាទទួលស្គាល់ថា បានបោះបង្គោលចូលមកដីខ្មែរពិតមែន ក្នុងសារលិខិតសរសេររួមគ្នាថ្វាយព្រះករុណាព្រះបាទសម្តេចនរោត្តម-សីហនុ ចុះថ្ងៃទី១៦ វិច្ឆិកា ២០០៩ ដែលព្រះអង្គបានស្នើសុំឲ្យអ្នកដឹកនាំទាំងបី ឲ្យពិនិត្យមើលប្រជាពលរដ្ឋនៅស្រុកចន្ទ្រា ខេត្តស្វាយរៀងដែលចោទថា យួនបានបោះបង្គោលរំលោភយកដីស្រែរបស់ខ្លួនអស់ជាច្រើនហិកតា ។ យើងសូមដកស្រង់នូវវគ្គខ្លះនៃសារលិខិតនោះថា ៖ «ដូចព្រះករុណាជាអម្ចាស់ទ្រង់ជ្រាបហើយ ព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ត្រូវបានប្រទេសទាំងពីរឯកភាពគ្នា អនុវត្តតាមសន្ធិសញ្ញាឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ។ល។ មួយចំណែកទៀត នៅក្នុងការបោះបង្គោលនិងខណ្ឌសីមាព្រំដែននេះ គឺធ្វើឡើងទៅតាមផែនទីមូលដ្ឋាន ដែលព្រះប្រមុខរដ្ឋបានយកទៅដំកល់នៅអង្គការសហប្រជាជាតិនាឆ្នាំ១៩៦៤ ។ ទោះបីជាយើងប្រើបច្ចេកទេសខ្ពស់យ៉ាងណាក្តី ការកំណត់ព្រំដែនយកតាមផែនទី និងការកាន់កាប់លើដីជាក់ស្តែងពុំដូចគ្នាទេ ដែលជាហេតុធ្វើឲ្យកន្លែងខ្លះឃើញថា ខ្សែព្រំដែនជ្រុលចូលទៅខាងក្នុងកន្លែង ដែលកាន់កាប់ដោយភាគីម្ខាងទៀត ជាហេតុបង្កើតជាបញ្ហាឲ្យគណៈកម្មការព្រំដែននៃប្រទេសទាំងពីរ ធ្វើការសំរុះសំរួលគ្នា» ។ល។

ក្នុងសេចក្តីនៃវគ្គក្នុងសារលិខិតដែលបានដកស្រង់មកខ្លះនេះ គួរពិចារណាថា បើមានផែនទីឆ្នាំ១៩៦៤ ដែលដំកល់នៅ

អង្គការសហប្រជាជាតិហើយ តើចាំបាច់មានសន្និសញ្ញាឆ្នាំ១៩៨៥ធ្វើអ្វីទៀត ? ឬឃួនកំណត់ផែនទីថ្មីដើម្បីឲ្យខ្មែរអនុវត្តតាម ? ឯការពោលថា យកផែនទីឆ្នាំ១៩៦៤នោះ គ្រាន់តែជាខែលទេ ។

ពាក្យថា «ការយកតាមផែនទី និងការយកតាមដីកាន់កាប់ជាក់ស្តែងពុំដូចគ្នាទេ ខ្សែព្រំដែនចូលទៅដីភាគីម្ខាងទៀត» នេះជាពាក្យទទួលស្គាល់ដោយប្រយោលថា បានបោះបង្គោលចូលមកដីស្រែរបស់ប្រជាពលរដ្ឋខ្មែរពិតមែន ហើយពុំបានចូលទៅដីស្រែចំការរបស់ប្រជាពលរដ្ឋវៀតណាមឡើយ ព្រោះប្រជាពលរដ្ឋវៀតណាមពុំស្រែកថាបាត់បង់ទឹកដីដូចពលរដ្ឋខ្មែរទេ ។ ជាការធម្មតា ប្រជាពលរដ្ឋកាលណាបើឃើញគេបោះបង្គោលរំលោភយកដីរបស់ខ្លួន ត្រូវតែដកចោល ព្រោះជាដីកេរមត៌ករបស់ខ្លួន ។ ការដកអភ័យឯកសិទ្ធិពីលោកសម-រង្ស៊ី គេមើលឃើញថា ជាការធ្វើតាមបញ្ជារបស់នាយករដ្ឋមន្ត្រីវៀតណាមសុទ្ធសាធ ។ ឯសភាប្រជុំគ្នាក្នុងរយៈពេលខ្លី តាមពត៌មានថាប្រហែល១០នាទី គ្មានពិភាក្សា បិទមិនឲ្យអ្នកខាងក្រៅចូលទៅស្តាប់ មានលក្ខណៈដូចសភារបស់ពួកខ្មែរក្រហម ដែលរង់ចាំធ្វើតាមតែបញ្ជារបស់មជ្ឈិមបក្សប៉ុណ្ណោះ ។

បើចង់ឲ្យទឹកដីខ្មែរគង់វង់ ខ្មែរនិងខ្មែរមិនត្រូវយកគ្នាជាសត្រូវឡើយ យ៉ាងណាមិញ រាជរដ្ឋាភិបាលខ្មែរមិនត្រូវយកអ្នកមានយោបល់អំពីបញ្ហាទឹកដី ដែលមិនស្របតាមយោបល់រាជរដ្ឋាភិបាល ជាសត្រូវស៊ីសាច់ហុតឈាមឡើយ ។ ការបញ្ចេញមតិស្របនិងផ្ទុយ ជាការធម្មតានៅក្នុងប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ ហើយនេះជាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការការពារផលប្រយោជន៍ខ្លួន និងប្រទេសរបស់ខ្លួន ។ គួរប្រមូលមតិទាំងអស់ ទាំងគណបក្សជំទាស់ អង្គការក្រៅរដ្ឋាភិបាល ជាពិសេសគណៈកម្មាធិការព្រំដែនកម្ពុជានៅប្រទេសបារាំង ដើម្បីដោះស្រាយបញ្ហាទឹកដីនេះ កុំឲ្យបាត់បង់តទៅទៀត ។ កុំពោលដដែលៗ អំពីថ្ងៃ៧ មករា ១៩៧៩ វាយប្រហារគេឯងស្មើររាល់ថ្ងៃយ៉ាងនេះឡើយ ។៚

❊ ❊

❊